# ខ្ទឹមបារាំង



ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម
គំរោងឥណទានកម្មវិធី ធនាគារ អភិវឌ្ឍន៍ អាស៊ី
(ADB) លេខ 1445 - CAM (SF)
ឆ្នាំ ២០០៥

# ដំណាំខ្ទឹមបារាំង

ម.ព.ឯ.ក AIDOC
Code: 248-037
Date:
Donated by:

## I. ស្ថានភាពទូទៅ

ខ្ទឹមបារាំងជាបន្លែមួយប្រភេទយ៉ាងសំខាន់សម្រាប់បំរើការហូបចុករបស់មនុស្សយើង ។ មើមខ្ទឹមបារាំងអាចនាំមកនូវជីវជាតិផ្សេងៗដូចជា : វីតាមីន និង ជាតិកាល់ស្យូមដែលអាចឱ្យមនុស្សមានសុខភាពមាំមួន កម្លាំងខ្លាំងក្លា ។ គេអាចយកខ្ទឹមបារាំង ទៅធ្វើជាម្ហូបអាហារដូចជា យកទៅឆារ ស្ងោរ ញាំ ឬធ្វើបន្លែសម្លរការី ។ល ។





## ១.ការជ្រើសរើសពូជ

ត្រូវជ្រើសរើសយកពូជដែលមានគុណភាពល្អទៅដាំព្រោះពូជល្អអាចនាំមកនូវភោគផលល្អ មើមធំទិន្នផលខ្ពស់ យកពូជដែលមានរយៈពេលដាំដុះខ្លីធន់ទ្រាំនឹងជម្ងឺ ឬ សត្វល្អិតបំផ្លាញ ។ ជ្រើសរើសយកពូជដែលមានអត្រាដុះពី ៨០-៩៥ % មានរសជាតិឆ្ងាញ់។ ឧទាហរណ៍



ពូជ GRANEX HYBRIDE ឬពូជ RED CREOL ដាំបានល្អនៅប្រទេសកម្ពុជាយើង ។

## ២. ការជ្រើសរើសដីដាំដុះ

ត្រូវជ្រើសរើសរកដីទួលមិនលិចទឹក មានពន្លឺថ្ងៃគ្រប់គ្រាន់ ។ ដីដែលដាំបានបរិមាណផលច្រើនគឺប្រភេទដីល្បាយខ្សាច់ដូចជាដីតាមមាត់ទន្លេ ឬដីដែលសំបូរជាតិហ្វូសស្វាត និងប៉ូតាស្យូម ។ ត្រូវរកដីធូរល្អនៅជិតប្រភពទឹក ឬមានប្រភពទឹកគ្រប់គ្រាន់ដូចជាត្រពាំង បឹងបួរ ព្រែក ស្រះអណ្តូង ឬ នៅជិតកន្លែងមានប្រព័ន្ធធារាសាស្រ្តពិសេសរកដីដែលនៅជិតភូមិដ្ឋានដើម្បីងាយស្រួលដល់ការថែទាំ ស្រោចទឹកបោចស្មៅ



និង ការពារ ។





### ៣. រដូវកាលដាំដុះ

នៅចុងរដូវភ្លៀង គេដាំខ្ទឹមបារាំងបាន ដោយស្រោចទឹក ។ រដូវដែលល្អជាងគេ សម្រាប់ដំណាំខ្ទឹមបារាំងគឺរដូវរំហើយ ដែលមានធាតុអាកាសត្រជាក់ល្អ ។

### ៤. របៀបដាំខ្ទឹមបារាំង

**ក.ការរៀបចំដីធ្វើថ្នាល និងធ្វើថ្នាលសាប**

-ភ្ជួរដីឱ្យបាន ២ ឬ ៣ ដង ហើយឱ្យបានជម្រៅពី ១៥ ទៅ ២០ ស.ម ។

-ត្រូវវាយបំបែកដីឱ្យម៉ត់ល្អដើម្បីឱ្យខ្យល់អាកាសចេញចូលបានស្រួល ទឹកងាយជ្រាបចូល រក្សាសំណើមបានយូរនិងអាចឱ្យឫសខ្ទឹមបារាំងចាក់ចូលក្នុងដី ស្រូបយកជីជាតិបានស្រួល ។



## ខ. របៀបធ្វើថ្នាល

ថ្នាលសាបអាចយកទទឹងពី ០,៨០ ម ទៅ ១ ម បណ្ដោយតាមលទ្ធភាពដី កម្ពស់ពី ០,១០ម ទៅ ០,១៥ ម ។ គេអាចបណ្ដុះគ្រាប់ខ្ទឹមបារាំងនៅក្នុងឡាំង ឬ កេសឈើ ដែលងាយស្រួលដល់ការលើកដាក់ចុះឡើង ។

**សេចក្ដីបញ្ជាក់ :** ដំណាំខ្ទឹមបារាំងគេអាចសាបផ្ទាល់លើរង តែត្រូវសាបឱ្យ



ស្មើហើយស្តើង។ បើដាំរបៀបនេះត្រូវដកចេញនូវកូនខ្ទឹមដែលអន់គុណភាព មានជម្ងឺ ឬ សត្វល្អិតបំផ្លាញ ។ គេអាចទុកតែមួយដើមក្នុងមួយគុម្ព នៅពេលកូនខ្ទឹមដុះបានពីមួយអាទិត្យទៅ ១០ ថ្ងៃ ។

### គ. របៀបដាក់ជីមុនពេលព្រោះគ្រាប់

ពេលធ្វើថ្នាលសាបបានត្រឹមត្រូវហើយត្រូវយកជីមករាយឱ្យស្មើរួចកាប់ត្រឡប់ទៅក្នុងដី រាស់ឱ្យស្អាត ។

### កំរិតជីដែលត្រូវប្រើ :

-ជីលាមកគោចំនួន ៣ គ.ក្រ ក្នុងដី ១ ម²

- ជី ១៥.១៥.១៥ ចំនួន ៣០ ក្រ ក្នុងដី ១ ម²

- ជីអាចម៍មាន់ចំនួន ៣០០ ក្រ ក្នុងដី ១ ម²

## ឃ. ការសាប ឬព្រោះគ្រាប់

ត្រូវយកគ្រាប់ខ្ទឹមទៅលាយជាមួយជាមួយដីខ្សាច់ម៉ត់ ឬផេះ ( គ្រាប់មួយ ភាគ លាយដីខ្សាច់ ឬ ផេះបួនភាគ) រួចយកទៅសាបឬព្រោះឱ្យស្តើងៗលើថ្នាល ។ គ្រាប់ខ្ទឹមបារាំងចំនួន ៣ ក្រាមលាយជាមួយដីខ្សាច់ម៉ត់ឬផេះ ១២ ក្រាម ( មួយភាគបួន) អាចព្រោះលើថ្នាល ១ ម$^{២}$ ។ ក្រោយពេលសាបត្រូវកាត់ចំបើងខ្លីៗទៅគ្របពីលើ ដើម្បីឱ្យទឹកដក់លើថ្នាលបានយូរ ។ ត្រូវស្រោចទឹកឱ្យបាន ៣ ដងក្នុង ១ ថ្ងៃ





ដោយប្រើធុងដែលមានផ្កាឈូកជៀសវាងគ្រាប់ខ្ទាតកកជុំៗ ។ ត្រូវយកផេះរោយជុំវិញថ្នាលការពារស្រមោចចូលស៊ីគ្រាប់ខ្ទឹម ។ ត្រូវគ្របថ្នាលលុះត្រាតែកូនខ្ទឹមបារាំងចេញពន្លកទើបបើកចេញ ។



## ង. ការរៀបចំដី និងលើករង

- ត្រូវភ្ជួរ ឬ កាប់ឱ្យបានច្រើនសារហើយបានជម្រៅ ២០ ស.ម រួចវាយបំបែកដីឱ្យម៉ត់ដើម្បីលើករងដាំ ។ ត្រូវលើករងឱ្យដូចៗគ្នាកម្ពស់ ១០ ស.ម ទទឹង ១ ម បណ្តោយតាមលទ្ធភាពដីដែលមាន ។



## ច. ការដាំដុះ

ត្រូវដកកូនដាំនៅពេលរសៀលត្រជាក់ដើម្បីកុំឱ្យកូនខ្ទឹមស្វិត ឬ ស្លោកដោយសារកំដៅថ្ងៃ ។ គេអាចដកកូនខ្ទឹមបារាំងទៅដាំនៅពេលវាមានអាយុ ៣០ ទៅ ៣៥ ថ្ងៃ គឺនៅពេលឃើញមានស្លឹក ៣ ទៅ ៤ ហើយជ្រើសយកកូនណាល្អ ដើមធំរឹងមាំ គ្មាន



ជម្ងឺ ឬសត្វល្អិតបំផ្លាញ ។ ក្រោយពេលដាំរួចភ្លាម ត្រូវគ្របឱ្យបាន ៣ ថ្ងៃ ដើម្បីឱ្យដីរក្សាសំណើមបានយូរ ។ ត្រូវស្រោចទឹកឱ្យបានសមស្រប ។

### របៀបដាំ

-ចន្លោះជួរ 0,១៥ ម

-ចន្លោះគុម្ព 0,១0 ម

- ក្រាលចំបើង ឬ ពុំចាំបាច់ក្រាលក៏បាន

## ឃ. ការប្រើប្រាស់ជីក្នុងផ្ទៃដី ១ ម²

ការដាក់ជីនេះមាន ២ របៀប

### របៀបទី ១ :

លើកទី ១ : មុនពេលលើករងដាំ

-ជីលាមកគោ ក្របី ចំនួន ៣ ទៅ ៥ គ.ក្រ

- ជីផេះ ចំនួន ១០០ គ.ក្រ

- ជីគីមី ១៥.១៥.១៥ ចំនួន ៣០ ទៅ ៥០ ក្រ

លើកទី ២ : ពេលខ្ទឹមបារាំងចាប់ផ្តើមមើម ( ក្រោយពេលស្ទូង ១ ខែ )

-ជីគីមី ១៥.១៥.១៥ ចំនួន ៣០ ក្រាម

- ស្រោចជីអ៊ុយរ៉េ ២ ស្លាបព្រាបាយលាយជាមួយទឹក ២០ លីត្រ ( ១ អាទិត្យស្រោច ១ ដងចាប់ស្រោចពេលដាំរួច )។



## របៀបទី ២ :

លើកទី ១ : មុនពេលលើករងដាំ

-ជីអាចម៍មាន់ចំនួន ៣០០ ក្រ

-ជីគីមី ១៥.១៥.១៥ ចំនួន ៣០ ក្រាម

លើកទី ២ : ក្រោយពេលដាំ ១ ខែ

-ជី ១៥.១៥.១៥ ចំនួន ៣០ ក្រ

-ជីអ៊ុយរ៉េ ២ ស្លាបព្រាបាយលាយទឹក ២០ លីត្រស្រោច ១ អាទិត្យម្តង ក្រោយពេលដាំរួច ១ សប្តាហ៍ ។



## កំណត់សំគាល់

ខ្ទឹមបារាំងត្រូវការចាំបាច់នូវជីជាតិប៉ូតាស្យូម ដើម្បីបង្កបង្កើតមើមបានធំៗនិងច្រើន ។ ជីជាតិប៉ូតាស្យូមអាចមានច្រើននៅក្នុងផេះសំបកគរ ។ល។

## ៥. ការថែទាំ

- ស្រោចទឹក ព្រឹកល្ងាច បោចស្មៅ ជួយដីឱ្យធូរ ដើម្បីខ្យល់ចេញចូលបានស្រួលទឹកងាយជ្រាបចូលក្នុងដីរក្សាសំណើមបានយូរធ្វើឱ្យឫសខ្ទឹមបារាំងអាចស្រូបយកជីជាតិស្រួលព្រមទាំង ដើមដង ស្លឹក មើមដុះបានល្អ ។



## ជម្ងឺ និងសត្វល្អិតបំផ្លាញ

**ក/សត្វល្អិត :** ដោយសារខ្ទឹមបារាំងមានរសជាតិហឹរបណ្ដាលឱ្យសត្វល្អិតចង្រៃពុំសូវបំផ្លាញជាលក្ខណៈធ្ងន់ធ្ងរដូចបន្លែដទៃទៀតទេ ។ ចំពោះបន្លែនេះយើងសង្កេតឃើញដង្កូវពីប្រភេទដែលបំផ្លាញ :

**១. ដង្កូវស៊ីរូងស្រទាប់ស្លឹក ឬ ស៊ីរូងស្លឹក :** គេកំចាត់វាដោយប្រើថ្នាំម៉ាឡាចុង ៤ ស្លាបព្រាបាយលាយទឹក ២០ លីត្រ ឬ មួយប៉ោតប្រេងកាត ។

**២. ដង្កូវរុយ :** វាកាត់ស្លឹក និង ចោះស្លឹក ។ គេកំចាត់វាដោយប្រើថ្នាំពុលហ្វូសឌ្រីន ឬ មេវ៉ាំងហ្វុស ២ ស្លាបព្រាបាយលាយទឹក ២០ លីត្រ ឬ មួយធុងបាញ់ថ្នាំ ។

**ខ/ ជម្ងឺ :**

ឆ្លងកាត់ការដាំដុះកន្លងមក គេតែងសង្កេតឃើញមានជម្ងឺមួយចំនួនកើតនៅលើខ្ទឹមបារាំង ជម្ងឺទាំងនោះច្រើនបណ្ដាលមកពីផ្សិត បាក់តេរី ណេម៉ាតូត វីរុស និងជម្ងឺបណ្ដាលមកពីទីកន្លែងពុំសមស្របជាដើម ។

**ដើម្បីកំចាត់ជម្ងឺទាំងនេះត្រូវ :**

-បាញ់ថ្នាំការពារដំណាំ

-ដាំឆ្លាស់មុខដំណាំ

-បាញ់ថ្នាំពពួក Fongicides លើគ្រាប់ពូជ និងដំណាំកំពុងលូតលាស់

- គាស់ ឬ ដកដុតចោលឆ្ងាយពេលឃើញមានកើតជម្ងឺនៅលើដើម ឬ គុម្ពណាមួយ ។



-ជ្រើសរើសពូជដែលធន់ទ្រាំនឹងជម្ងឺ

## II. ការប្រមូលផល

គេអាចប្រមូលផលបាននៅពេលដែលស្លឹករបស់វាចាប់ផ្ដើមងាប់ សំបកមើមឡើងពណ៌ក្រហម ឫស និងមើមលេចចេញពីដី ពូជខ្លះមានរយៈពេលលូតលាស់ពី ១២០ទៅ ១៧០ ថ្ងៃក្រោយពេលសាប ទិន្នផលខ្ទឹមបារាំងអាចផ្ដល់ជាមធ្យមពី ៣០ ទៅ ៧០ ត/ហ.ត ។



## III. ការថែរក្សាទុក

ចង់រក្សាមើមខ្ទឹមបារាំងទុកបានយូរ ថ្ងៃត្រូវទុកទាំងស្លឹក រួចចងជាដុំព្យួរ ឱ្យផុតពីដី ដាក់នៅកន្លែងដែលមាន អាកាសធាតុត្រជាក់ មានខ្យល់ចេញ ចូលល្អ មានសីតុណ្ហភាពក្រោម ១០ អង្សាសេ ។ នៅប្រទេសកម្ពុជាយើង ពុំអាចរក្សាពូជខ្ទឹមបារាំងបានល្អទេ ដោយសារអាកាសធាតុក្តៅពុំសម ស្របនិងសេចក្តីត្រូវការសម្រាប់ ពូជខ្ទឹមបារាំង ។



